**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង

ថ្ងៃទីប្រាំបី ខែកក្កដា ឆ្នាំពីពាន់ដបបួន វេលាម៉ោងប្រាំបីនិងសាមសិបនាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី មានរៀបចំកិច្ចប្រជុំអន្តរក្រសួងមួយក្រោមអធិបតីភាព ឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសសកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានគណៈកម្មការអន្តរក្រសួង ដោយមានការចូលរួមពីសំណាក់សមាជិកគណៈកម្មការ និងតំណាងភ្នាក់ងារឯករាជ្យ ដូចមានឈ្មោះក្នុងបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

- របាយការណ៍របស់ក្រុមការងារបច្ចេកទេស
- សំណូមពររបស់ប្រជាពលរដ្ឋរងផលប៉ះពាល់
- សេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារដោះស្រាយបណ្តឹងតវ៉ា។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** ប្រធានអង្គប្រជុំ បានស្វាគមន៍ចំពោះសមាជិកអង្គប្រជុំទាំងអស់ និងបានលើកឡើងថា កិច្ចប្រជុំនេះយើងនឹងពិនិត្យពិភាក្សាលើបញ្ហាបីខាងលើ និងដើម្បីអង្គប្រជុំមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់កិច្ចពិភាក្សា **ឯកឧត្តម ទេសរដ្ឋមន្ត្រី** ប្រធានអង្គប្រជុំបានអនុញ្ញាតឲ្យ **ឯកឧត្តម សយ សុខាន់** អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងជាប្រធានក្រុមការងារបច្ចេកទេសធ្វើសេចក្តីរាយការណ៍លម្អិតអំពីស្ថានភាពការងាររួមជូនអង្គប្រជុំជ្រាប។

**ឯកឧត្តម សយ សុខាន់** បានបញ្ជាក់ជូនដូចតទៅ៖

I) **ស្ថានភាពរួម**

តំបន់សន្តិសុខ និងតំបន់សុវត្ថិភាពជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលត្រូវរៀបចំឲ្យស្របតាមកំរិតអប្បរិមានៃស្តង់ដា អង្គការ ICAO មានផ្ទៃដីសរុបទំហំ ៧,៤៥ហ.ត ក្នុងនោះមាន៖

- ផ្ទៃដីតំបន់សន្តិសុខ = ២,៧១ ហ.ត
- ផ្ទៃដីតំបន់សុវត្ថិភាព = ៤,៧២ ហ.ត
- បរិវេណដែលត្រូវបោះបង្គោលប្រវែង = ៦០៣០ ម
- គ្របដណ្តប់លើភូមិ០៥ (ព្រៃជីសាក់ ថ្មគោល គោកចំបក់ ស្ថិតក្នុងសង្កាត់ចោមចៅ និងត្រពាំងល្វា តាងួន ស្ថិតក្នុងសង្កាត់កាកាប ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ)។

ក) ការងារបោះបង្គោល

ក្រុមការងារបច្ចេកទេសបានចុះបង្គោល កំណត់ព្រំខ័ណ្ឌ តំបន់សន្តិសុខ និងតំបន់សុវត្ថិភាព ចាប់ពីថ្ងៃទី ២៤ ខែមេសា - ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ដែលជាលទ្ធផលមានដូចខាងក្រោម៖

- បោះបង្គោលបានចំនួន០៣ភូមិ (ព្រៃជីសាក់ ថ្មគោល គោកចំបក់ ស្ថិតក្នុងសង្កាត់ចោមចៅ) លើបរិវេណដីប្រវែង ៥២៦០ម ។
- ការងារបង្គោលត្រូវបានផ្អាកនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ដោយប្រជាពលរដ្ឋភូមិត្រពាំងល្វា ពុំយល់ព្រមឲ្យបោះបង្គោល។

ខ) ការវាស់វែងលម្អិត និងការសម្រង់ស្ថិតិ

ភ្នាក់ងារឯករាជ្យ បានចុះវាស់វែង និងសម្រង់ស្ថិតិចាប់ពីថ្ងៃទី២៥ ខែមេសា រហូតបច្ចុប្បន្ន ជាលទ្ធផលមានដូចខាងក្រោម៖

១) ភូមិព្រៃជីសាក់

- ផ្ទៃដីសរុបទំហំ = ៥៥,៩១៩.៨២ម២ (ក្នុងនោះមាន ផ្ទៃដីលំនៅដ្ឋានទំហំ = ៤៧,៤០៥.៨៩ម២ និង ផ្ទៃដីទំនេរទំហំ = ៨,៥១៣.៩៣ម២)។
- ប៉ះពាល់ប្រជាពលរដ្ឋ ២២៣ គ្រួសារ ក្នុងនោះ (សម្រង់បាន ២១៦ គ្រួសារ, មិនអាចទំនាក់ទំនងបាន ០៦ គ្រួសារ និងចំផ្លូវចេញ-ចូល ០១ គ្រួសារ) ។

២) ភូមិថ្មគោល

- ផ្ទៃដីសរុបទំហំ = ៩,២៣០.៦៦ម២ (ក្នុងនោះមាន ផ្ទៃដីលំនៅដ្ឋានទំហំ = ៤,០៩៦.៩៤ម២ និងផ្ទៃដីទំនេរទំហំ = ៥,១៣៣.៧២ម២ )។
- ប៉ះពាល់ប្រជាពលរដ្ឋ ២១៦ គ្រួសារ (សម្រង់បាន ១៩៦ គ្រួសារ, មិនអាចទំនាក់ទំនងបាន ១៦ គ្រួសារ និង ០៤ គ្រួសារទៀតបំពេញបែបបទមិនទាន់ចប់ ហើយក្រោយមកបានបាត់ទំនាក់ទំនងគ្នាតែម្តង) ។

៣) ភូមិគោកចំបក់

- ផ្ទៃដីសរុបទំហំ = ៣,៥៥៦.៩០ម២ (ក្នុងនោះមាន ផ្ទៃដីលំនៅដ្ឋានទំហំ = ៥២៩,៦២ម២ និង ផ្ទៃដីទំនេរទំហំ = ៣,០២៧.២៨ម២)
- ប៉ះពាល់ប្រជាពលរដ្ឋ ០៩ គ្រួសារ (សម្រង់បាន ០៨ គ្រួសារ និង ០១គ្រួសារ បដិសេធ)។

II) **សំណូមពររបស់ប្រជាពលរដ្ឋរងផលប៉ះពាល់**

ក) ភូមិត្រពាំងល្វា និងភូមិតាងួន មានប្រជាពលរដ្ឋសរុបប្រមាណ ៦២ គ្រួសារ ពួកគាត់មិនអនុញ្ញាតឲ្យក្រុមការងារចុះបោះបង្គោលទេ ដោយបានបញ្ជាក់ថា ការបោះបង្គោលអាចអនុញ្ញាតឲ្យបានលុះណាតែគណៈកម្មការបញ្ជាក់ឲ្យបានច្បាស់ ជាលាយលក្ខណអក្សរនូវសំណូមពរ៖

- អំពីតំលៃដី
- ក្រោយពីវាស់វែងបោះបង្គោលរួច ចេញប្លង់កម្មសិទ្ធិជូនពួកគាត់បានឬទេ?
- ថាតើនណាជាអ្នកចេញថវិកាដោះស្រាយផលប៉ះពាល់ (រដ្ឋាភិបាល ឬ ក្រុមហ៊ុន SCA)

ខ) ប្រជាពលរដ្ឋភូមិព្រៃជីសាក់ ភូមិថ្មគោល និងភូមិគោកចំបក់សំណូមពរឲ្យគណៈកម្មការបន្តការងារដោយមិនចាំបាច់រងចាំ ភូមិត្រពាំងល្វា និងភូមិតាងួនទេ។

III) **សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារដោះស្រាយបណ្តឹងតវ៉ា**

ដើម្បីឲ្យការអនុវត្តប្រព្រឹត្តទៅស្របតាមនីតិវិធី ក្រុមការងារបច្ចេកទេសបានរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារដោះស្រាយបណ្តឹងតវ៉ា។ ក្រុមការងារនេះមានសមាសភាពមកពីអាជ្ញាធរដែនដីពាក់ព័ន្ធ និងមានភារកិច្ចជួយរកដំណោះស្រាយជូនប្រជាពលរដ្ឋរងប៉ះពាល់ ក្នុងករណីដែលពួកគាត់មិនពេញចិត្តលើគោលការណ៍ដោះស្រាយផលប៉ះពាល់ណាមួយ។

បន្ទាប់ពី**ឯកឧត្តម សយ សុខាន់** បានធ្វើសេចក្តីរាយការណ៍លម្អិតជូនអង្គប្រជុំរួចមក **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអង្គប្រជុំបានបញ្ជាក់ជូនថា ចំពោះតំលៃដីគណៈកម្មការបានជម្រាបជូនពួកគាត់រួចរាល់ហើយ តាមរយៈកិច្ចប្រជុំថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៤ តំលៃដីអាចកំណត់បានបន្ទាប់ពីភ្នាក់ងារឯករាជ្យ ធ្វើការវាស់វែង និងសម្រង់ស្ថិតិលើផលប៉ះពាល់ និងសិក្សាអំពីតំលៃដីដោយឈរលើមូល

ដ្ឋានតំលៃស្មើឡើងដោយប្រជាពលរដ្ឋ តំលៃដីដែលកំណត់ដោយរដ្ឋ និងតំលៃដីទីផ្សារ ត្រូវបានបញ្ចប់ និងដាក់ជូនគណៈកម្មការពិនិត្យសម្រេច។

រីឯថវិកាសម្រាប់ដោះស្រាយគោលនយោបាយនោះ យើងក៏បានបញ្ជាក់ជូនពួកគាត់ហើយដែរ ថា នេះជាបន្ទុករបស់រាជរដ្ឋាភិបាល។ ចំពោះសំណើរបស់ប្រជាពលរដ្ឋ ភូមិព្រៃជីសាក់ ភូមិថ្មគោល និងភូមិគោកចំបក់ យើងគួរឯកភាព ដោយអនុញ្ញាតឲ្យភ្នាក់ងារឯករាជ្យបន្តការងារនៅមូលដ្ឋានបន្តទៀត ដោយមិនរងចាំភូមិត្រពាំងល្វា និង ភូមិតាងួនទេ។ ដោយឡែកការសុំឲ្យចេញប្លង់កម្មសិទ្ធិបន្ទាប់ពីការវាស់វែងយើងមិនអាចឆ្លើយតបបានទេ ដូច្នេះសុំឲ្យអង្គប្រជុំចូលរួមមតិលើករណីខាងលើនេះ។

**ឯកឧត្តម ប៊ុន រដ្ឋា** បានបញ្ជាក់ជូនថា គួរឯកភាពតាមសំណើរបស់ប្រជាពលរដ្ឋភូមិព្រៃជីសាក់ ភូមិថ្មគោល និងភូមិគោកចំបក់ ដោយរក្សាទុក ភូមិត្រពាំងល្វា និងភូមិតាងួន ដោះស្រាយនៅពេលក្រោយ។

**ឯកឧត្តម គឹម សុវណ្ណ** បានបញ្ជាក់ថា គួរដោះស្រាយបណ្តើរៗ ដើម្បីជាគំរូសម្រាប់ភូមិដែលមិនទាន់ឯកភាព។ ម្យ៉ាងទៀតពួកគាត់សុទ្ធតែមានមេខ្យល់ផងដែរ។ ពាក់ព័ន្ធនឹងការចេញប្លង់កម្មសិទ្ធិសុំឲ្យអាជ្ញាធរខ័ណ្ឌ សហការជាមួយជំនាញនគរូបនីយកម្មសិក្សាជាលក្ខណៈប្រយោលសិនថាតើក្រោយពីវាស់វែងហើយពួកគាត់នៅសល់ដីសម្រាប់ចេញប្លង់កម្មសិទ្ធិដែរឬទេ ព្រោះដីពួកគាត់ខាងក្រោយប៉ះនឹងតំបន់សន្តិសុខ និងខាងមុខប៉ះនឹងចំណីផ្លូវ។ គួរកែសម្រួលសមាសភាពគណកម្មការព្រោះថា ចៅហ្វាយខ័ណ្ឌត្រូវបានផ្លាស់ប្តូរថ្មី។

**លោក យិន គា** បានបញ្ជាក់ថា គួរឯកភាពបន្តការងារសម្រាប់ភូមិព្រៃជីសាក់ ភូមិថ្មគោល និងភូមិគោកចំបក់ ដោយមិនចាំបាច់រង់ចាំភូមិ០២ទៀតទេ ។ ពាក់ព័ន្ធសំណើរបស់ប្រជាពលរដ្ឋភូមិត្រពាំងល្វា ខ័ណ្ឌនឹងសុំឲ្យក្រុមការងារខ័ណ្ឌសិក្សាឲ្យបានច្បាស់លាស់អំពីដីរបស់ពួកគាត់ដែលនៅចន្លោះតំបន់សន្តិសុខនិងចំណីផ្លូវថាតើក្រោយពីវាស់វែងរួចអាចចេញប្លង់កម្មសិទ្ធិបានឬអត់។

**ឯកឧត្តម ម៉ម សុជាណា** បានបញ្ជាក់ថា សុំគាំទ្រចំពោះសំណើរបស់ប្រជាពលរដ្ឋភូមិ០៣ខាងលើ ដែលបានសហការល្អ និងសុំឲ្យពន្យល់ ឬ បញ្ជាក់ឲ្យបានច្បាស់លាស់ទៅនឹងផ្លូវច្បាប់។

**លោក សែស សុខកុសល** តំណាងសាលារាជធានីភ្នំពេញ បានបញ្ជាក់ថា ឯកភាពឲ្យបន្តការងារសម្រាប់ភូមិ០៣ ដែលបានសហការ។ ចំពោះភូមិ០២ ដែលមិនសហការ គួរអនុវត្តតាមសារាចរលេខ០៣ និងអនុក្រឹត្យលេខ០៦។ ចំពោះការចេញប្លង់កម្មសិទ្ធិជាក់ស្តែងការពង្រីកផ្លូវវែងស្រេង អាចចេញបាន បន្ទាប់ពីការធ្វើ DMS ត្រូវបានបញ្ចប់និងសំណងត្រូវបានដោះស្រាយរួច។ រីឯសមាសភាពក្រុមការងារដោះស្រាយបណ្តឹងតវ៉ា គួរមានសមាសភាពប្រជាពលរដ្ឋរងការប៉ះពាល់ចូលរួម។

បន្ទាប់ពីបានពិនិត្យនិងពិភាក្សាយ៉ាងយកចិត្តទុកដាក់ចំពោះបញ្ហាខាងលើនេះ រួចមកអង្គប្រជុំបានសម្រេចដូចខាងក្រោម៖

- ឯកភាពតាមសំណើរបស់ប្រជាពលរដ្ឋភូមិព្រៃជីសាក់ ភូមិថ្មគោល និងភូមិគោកចំបក់ ដោយអនុញ្ញាតឲ្យភ្នាក់ងារឯករាជ្យបន្តដំណើរការ ការងារតាមកម្មវិធីដែលបានគ្រោងទុក។
- ចំពោះភូមិត្រពាំងល្វា និងភូមិតាងួន គណៈកម្មការសុំឲ្យផ្អាក និងបន្តការសម្របសម្រួលជាមួយពួកគាត់ជាបន្តទៀត។
- ដើម្បីឲ្យក្រុមការងារមានមូលដ្ឋានគ្រប់គ្រាន់ សម្រាប់បន្តការងារជាមួយប្រជាពលរដ្ឋភូមិត្រពាំងល្វា និងភូមិតាងួន សុំឲ្យអាជ្ញាធរខ័ណ្ឌសហការជាមួយក្រុមជំនាញសិក្សាជាលក្ខណៈប្រយោលថា ក្រោយពីកាត់តំបន់សន្តិសុខប្រវែង៥ម ចេញ និងដកចំណីផ្លូវរួចតើមានប៉ុន្មានគ្រួសារមានដីនៅ

សល់ និងប៉ុន្មានគ្រួសារត្រូវអស់ដី ហើយបន្ទាប់មកផ្តល់ទិន្នន័យនោះមកក្រុមការងារបច្ចេកទេស ដើម្បីឆ្លើយតបទៅប្រជាពលរដ្ឋវិញ។

- ឯកភាពឲ្យបញ្ចូលតំណាងប្រជាពលរដ្ឋរងផលប៉ះពាល់ ជាសមាជិកក្រុមការងារដោះស្រាយបណ្តឹងតវ៉ា។

- ដើម្បីពន្លឿនការងារនេះ សុំឲ្យសាលារាជធានីភ្នំពេញ ជួយបំពេញសមាសភាព និងកែសម្រួល សេចក្តីព្រាង សេចក្តីសម្រេចនេះ បើយល់ថា ចាំបាច់នឹងបញ្ជូនមកគណៈកម្មការវិញ ក្នុងរយៈពេលមួយសប្តាហ៍ ប្រសិនបើអាចធ្វើទៅបាន។

- គណៈកម្មការអន្តរក្រសួងរៀបចំសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដោយដាក់ឈ្មោះអភិបាលខណ្ឌពោធិ៍សែនជ័យថ្មីជំនួសអភិបាលខណ្ឌចាស់ ដើម្បីស្នើសុំការសម្រេចពី **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់និងហាសិបប្រាំនាទីព្រឹក នាថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសរីករាយស្និទ្ធស្នាលប្រកបដោយស្មារតីឯកភាព និងទទួលខុសត្រូវខ្ពស់។

**អ្នកធ្វើរបាយការណ៍**

**លឹម ឈុនលាង**

**ប្រធានអង្គប្រជុំ**

**យឹម ឆាយលី**
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន គ.ស.ក**
**និងជាប្រធានគណៈកម្មការអន្តរក្រសួង**